## ការអំពាវនាវទៅកាន់ជំនាន់ដែលកំពុងពេញវ័យ

អែលឌើរ ប្រេន អេជ នៀលសិន
នៃពួកចិតសិបនាក់

*គ្មានការហៅ ឬកិច្ចការណាមួយធំជាងការបង្រៀនពី "ការទៅបញ្ចុះបញ្ចូល ឱ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឱ្យ ដោយនូវព្រះនាមនៃព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ" នោះទេ ។*

នៅពេលការបំរើលើផែនដីរបស់ព្រះអង្គសង្គ្រោះបានខិតចូលមកដល់ទីបញ្ចប់ នោះទ្រង់បានលេចមកជួបពួកសាវកររបស់ទ្រង់ ជារូបកាយដែលបានរស់ឡើងវិញ ។ ទ្រង់បានដាក់ការទទួលខុសត្រូវដល់ពួកគេដូចគ្នានឹងការហៅដែលទ្រង់បានប្រគល់មកដល់អ្នកនៃជំនាន់ដែលកំពុងពេញវ័យសព្វថ្ងៃនេះដែរថា: "ចូរទៅបញ្ចុះបញ្ចូលឱ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឱ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ" ( ម៉ាថាយ 28:19) ។

នៅថ្ងៃទី 6 ខែ មេសា ឆ្នាំ 1974 សាសនាចក្របានគាំទ្រដល់ព្យាការីថ្មី ប្រធាន ស្ពែនស៊ើរ ដបុលយូ឴ ឃីមបឹល ។ នៅថ្ងៃដដែលនោះខ្ញុំបានទទួលការហៅរបស់ខ្ញុំ ឱ្យបំរើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងនៅក្នុងប្រទេសហ្វាំងឡង់ ។ នៅពេលនោះខ្ញុំមិនបានដឹងថា ប្រធាន ឃីមបឹល ទើបតែបានផ្តល់ប្រសាសន៍ជាប្រវត្តិសាស្ត្រនៅសប្តាហ៍នោះទៅកាន់ពួកអ្នកមានសិទ្ធិអំណាចទូទៅ និងអ្នកតំណាងប្រចាំតំបន់នៃសាសនាចក្រទេ ។ ក្រោយមកខ្ញុំបានដឹងថា នៅក្នុងប្រសាសន៍ព្យាករណ៍របស់ប្រធាន ឃីមបឹល នោះបានបង្ហាញនូវទស្សនវិស័យរបស់លោកអំពីរបៀបដែលយើងក្នុងនាមជាសាសនាចក្រមួយ នឹងសម្រេចនូវភារកិច្ចរបស់ព្រះអង្គសង្គ្រោះដើម្បី "បង្រៀនដល់គ្រប់សាសន៍" ។ នៅក្នុងប្រសាសន៍របស់លោកប្រធាន ឃីមបឹល បានអញ្ជើញសមាជិកនៃសាសនាចក្រឱ្យបង្កើនការខិតខំរបស់ពួកគេ ហើយពង្រីកទស្សនវិស័យរបស់ពួកគេ ។ លោកបានសុំឱ្យយុវជនដែលមានភាពសក្តិសមគ្រប់រូបរៀបចំខ្លួនដើម្បីបំរើបេសកកម្មពេញម៉ោងដោយកិត្តិយស ។ លោកបានលើកទឹកចិត្តដល់សមាជិកនៅក្នុងប្រទេសនីមួយៗ រៀបចំខ្លួនឱ្យផ្គត់ផ្គង់ដល់ពួកអ្នកផ្សព្វផ្សាយរបស់ខ្លួន ហើយលោកបានហៅ "បុរសដែលមានសមត្ថភាពឱ្យជួយដល់[ពួកសាវក]ដប់ពីរនាក់ ដើម្បីឱ្យចេញទៅកាន់ពិភពលោក ហើយបើកទ្វារជាតិសាសន៍ទាំងឡាយ" ( "When the World Will Be Converted" *Ensign,* Oct. 1974, 10) ។

ប្រធាន ឃីមបឹល ក៏បានមានប្រសាសន៍នៅក្នុងប្រសាសន៍របស់លោកកាលពីឆ្នាំ 1974 ផងដែរថា ក្នុងចំណោមសមាជិកនៃសាសនាចក្រចំនួន 3.3 លាននាក់ មាន 18,600 នាក់ ជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង និងមានស្តេក ចំនួន 633 កន្លែង ។ លោកបានសំណូមពរឱ្យយើងធ្វើឱ្យកាន់តែល្អ ហើយសុំឱ្យយើងផ្លាស់ប្តូរគំនិតរបស់យើង ហើយលើកកំពស់ចក្ខុវិស័យរបស់យើង ( សូមមើល *Ensign,* ខែ តុលា ឆ្នាំ 1974 ទំព័រ 7--8) ។

នៅក្នុងការឆ្លើយតប ក្នុងនាមជាសមាជិកនៃសាសនាចក្រ ពួកយើងបានចាប់ផ្តើមអធិស្ឋាននៅក្នុងគ្រួសាររបស់យើង ជាប្រចាំនៅក្នុងការប្រជុំសាក្រាម៉ង់របស់យើង និងនៅក្នុងសន្និសីទស្តេករបស់យើង ដើម្បីបន្ទន់ចិត្តរបស់ពួកអ្នកដឹកនាំនៃជាតិសាសន៍

ទាំងឡាយ ហើយទ្វារត្រូវបានបើក សំរាប់ពួកអ្នកផ្សព្វផ្សាយសាសនារបស់យើង។ សមាជិកបានចាប់ផ្តើមមើលឃើញកាន់តែច្បាស់ អំពីការទទួលខុសត្រូវរបស់ពួកគេ ក្នុងការចែកចាយដំណឹងល្អ។ យុវជនរបស់យើងបានធ្វើតាមសំណូមពរ ហើយកងទ័ពនៃពួកអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យរបស់យើងត្រូវបានប្រមូលផ្តុំគ្នា។ យើងធ្វើជាសាក្សីចំពោះទស្សនវិស័យរបស់ប្រធាន ឃីមប៊ល ថា ចាប់ផ្តើមសម្តែងឡើង។

ខណៈពេលកំពុងបំរើនៅក្នុងប្រទេសហ្វាំងឡង់ ខ្ញុំបានដឹងថាប្រពន្ធប្រធានបេសកកម្មរបស់ខ្ញុំ ស៊ិស្ទើរ លី ម៉ាហាន់នី គឺជាជនជាតិហ្វាំងឡង់។ កាលពីគាត់នៅក្មេង គាត់បានធំឡើងនៅក្នុងប្រទេសហ្វាំងឡង់ប៉ែកខាងកើត នៅក្នុងទីក្រុងមួយ ឈ្មោះថា វីអ៊ីពូរី។ នៅពេលសង្គ្រាមទំលាយចូលព័ទ្ធជុំវិញប្រទេសហ្វាំងឡង់ និងប្រទេសផ្សេងទៀត អំឡុងពេលសង្គ្រាមលោកលើកទី II គាត់ និងក្រុមគ្រួសាររបស់គាត់បានចេញចោលផ្ទះ ហើយ វីអ៊ីពូរី បានក្លាយជាចំណែកនៃសហភាពសូវៀត ហើយត្រូវបានដាក់ឈ្មោះថ្មីថា វីប៊ឺហ្គ។ នៅក្នុងសន្និសីទហ្សូនរបស់យើង ស៊ិស្ទើរ ម៉ាហាន់នី ប្រាប់យើងអំពីមនុស្សទាំងឡាយ ដែលបានទុកចោលឱ្យនៅទីក្រុង វីអ៊ីពូរី ហើយគាត់មានបំណងប្រាថ្នាចង់នាំដំណឹងល្អទៅឱ្យពួកគេ។ បន្ទាប់ពីសំណូមពររបស់ប្រធាន ឃីមប៊ល យើងបានអធិស្ឋានប្រកបដោយសាមគ្គីភាព សុំឱ្យដួងចិត្តរបស់អ្នកដឹកនាំនៃជាតិសាសន៍នោះ ត្រូវបានបន្ទន់ ដើម្បីឱ្យដំណឹងល្អអាចត្រូវបាននាំទៅកាន់សហភាពសូវៀតដោយពួកអ្នកផ្សព្វផ្សាយសាសនារបស់យើង។

យើងនឹងទៅកាន់ព្រំដែនរវាងប្រទេសហ្វាំងឡង់ និងសហភាពសូវៀត ហើយមើលឃើញអ្នកយាមនៅលើប៉ម និងរបងជាច្រើន ហើយយើងបានឆ្ងល់ថាតើនរណានឹងជាយុវជន និងយុវនារីក្លាហានទៅហ្ន៎! ហើយតើពេលណាទើបពួកគេនឹងឆ្លងកាត់ព្រំដែននោះ ដើម្បីនាំយកដំណឹងល្អទៅកាន់ប្រជាជននៅទីនោះ។ ខ្ញុំត្រូវតែសារភាពថា នៅពេលនោះវាហាក់ដូចជាកិច្ចការដែលមិនអាចធ្វើទៅបានទេ។

កាលពីបីឆ្នាំមុន កូនប្រុសរបស់យើងឈ្មោះ អេរីក បានទទួលការហៅបេសកកម្មឱ្យបំរើនៅប្រទេសរ៉ុស្ស៊ី បេសកកម្មសេនភីធើរសាប៊ឺក ។ នៅក្នុងសំបុត្រដំបូងគេរបស់គាត់សរសេរមកផ្ទះ គាត់បានសរសេរនូវអ្វីមួយដូចនេះថា: "ជូនចំពោះលោកប៉ា និងអ្នកម៉ាក់ជាទីស្រឡាញ់ ខ្ញុំត្រូវបានចាត់ឱ្យទៅទីក្រុងដំបូងរបស់ខ្ញុំនៅប្រទេសរ៉ុស្ស៊ី។ ប៉ាប្រហែលជាធ្លាប់ឮ អំពីទីក្រុងនេះកាលពីមុនហើយ។ វាឈ្មោះថាទីក្រុង វីប៊ឺហ្គ ប៉ុន្តែកាលពីមុនវាជាទីក្រុងប្រទេសហ្វាំងឡង់ដែលមានឈ្មោះថា វីអ៊ីពូរី"។

ទឹកភ្នែករបស់ខ្ញុំបានស្រក់ចុះមក នៅពេលខ្ញុំបានដឹងថា អេរីក គឺកំពុងតែស្ថិតនៅក្នុងទីក្រុង ដែលខ្ញុំបានអធិស្ឋានអស់រយៈពេលប្រហែលជា 32 ឆ្នាំមុន។ អេរីក បានរកឃើញថាមានសាលាជំនុំមួយ និងមានសាខាមួយដែលមាន ពួកបរិសុទ្ធស្មោះត្រង់នៅទីនោះ។ គាត់កំពុងតែរស់នៅ និងកំពុងតែបំរើនៅក្នុងកន្លែងមួយ ដែលខ្ញុំកាលពីនៅក្មេងមើល ទៅហាក់ដូចជាមិនអាចចូលទៅបំរើបាន។

ខ្ញុំមិនបានដឹងថាអស់រយៈពេលជាច្រើនឆ្នាំកន្លងទៅ នៅពេលយើងបានអធិស្ឋានសុំឱ្យបើកព្រំដែន ហើយមានពួកអ្នកផ្សព្វផ្សាយសាសនាអាចចូលទៅ គឺជាពេលដែលខ្ញុំកំពុងតែអធិស្ឋានសំរាប់កូនប្រុសរបស់ខ្ញុំសោះ។ ដែលសំខាន់ជាងនោះ សំរាប់អ្នកដែលជា

ជំនាន់កំពុងពេញវ័យ កូនប្រុសរបស់យើង អេរីក មិនបានដឹងថា គាត់ និងដៃគូរបស់គាត់បានឆ្លើយតបចំពោះការអធិស្ឋានដែលត្រូវបានធ្វើឡើងដោយពួកបរិសុទ្ធស្មោះត្រង់រាប់ពាន់នាក់អស់ជាច្រើនឆ្នាំកន្លងមកនោះទេ ។ អ្នករាល់គ្នាដែលជាជំនាន់ពេញវ័យ គឺជាការបំពេញនៃការព្យាករណ៍នោះ នៅជំនាន់របស់យើងនេះ ។ "សេចក្តីពិតរបស់ព្រះនឹងទៅមុខដោយម៉ឺងម៉ាត់ ដោយថ្លៃថ្នូរ និងឯករាជ្យ រហូតដល់វាជ្រៀតចូលទៅគ្រប់ទាំងទ្វីប ក្នុងអាកាស បក់ទៅគ្រប់ប្រទេស ហើយបានស្តាប់ឮនៅគ្រប់ត្រចៀក រហូតដល់គោលបំណងរបស់ព្រះនឹងបានសម្រេច ហើយព្រះយេហូវ៉ាដ៏មហិមា នឹងមានបន្ទូលថា កិច្ចការបានចប់សព្វគ្រប់ហើយ" (យ៉ូសែប ស្ម៊ីធ នៅក្នុង *History of the Church* 4:540) ។

ចាប់តាំងពីការបង្រៀនដោយការព្យាករណ៍របស់ប្រធាន ឃីមបឹល កាលពី 35 ឆ្នាំមុន សមាជិកភាពនៃសាសនាចក្របានរីកចំរើនរហូតដល់មានសមាជិក 13.5 លាននាក់ ។ ឥឡូវមានអ្នកផ្សព្វផ្សាយសាសនា 52,000 នាក់ ហើយមានស្តេកនៃស៊ីយ៉ូនច្រើនជាង 2,800 កន្លែង ។ តើនរណាជាអ្នកធ្វើការនៅក្នុងចំការទំពាំងបាយជូរ ដែលបានជួយនៅក្នុងការនាំនូវកិច្ចការយ៉ាងអស្ចារ្យ ហើយចម្លែក? ច្បាស់ណាស់ថា ពួកលោក គឺជាពួកព្យាការី និងពួកសាវក ដែលបានអង្គុយនៅខាង មុខយើងនាថ្ងៃនេះ ។ ពួកលោកក៏ជាប្រធានស្តេក និងប៊ីស្សពដ៏អស្ចារ្យទាំងឡាយ ដែលបានបំរើយ៉ាងស្មោះត្រង់ផងដែរ ។ ប៉ុន្តែពួកលោកក៏ជាឪពុកម្តាយរបស់អ្នកផងដែរ---ជាឪពុក និងម្តាយ--- មីង ពូ និងបងប្អូនប្រុសស្រីរបស់អ្នក ដែលអង្គុយនៅជិតអ្នក ដែលអ្នករាល់គ្នាជាជំនាន់ដែលកំពុងពេញវ័យ ។ ទោះជាយ៉ាងណាក៏ដោយ ដែលសំខាន់ជាងនោះ គឺកត្តាដែលថា នៅពេលយើងព្យាយាមដើម្បីនាំដំណឹងល្អទៅកាន់មនុស្សគ្រប់ជាតិសាសន៍ នោះយើងទើបតែចាប់ផ្តើមសម្រេចការណ៍នេះប៉ុណ្ណោះ ។

ហេតុដូច្នេះហើយ ឥឡូវនេះការទទួលខុសត្រូវត្រូវបានប្រគល់ទៅឱ្យជំនាន់ដែលកំពុងពេញវ័យ ។ តាមរយៈព្យាការីរបស់ទ្រង់នាសព្វថ្ងៃនេះ គឺប្រធាន ថូម៉ាស អេស ម៉នសុន ព្រះអង្គសង្គ្រោះបានរំលឹកអំពីការហៅ នៅពេលលោកបានប្រកាសថា:

"គោលការណ៍សំខាន់របស់យើង ត្រូវបានបង្ហាញឡើងដោយព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់យើងដែលគង់នៅជាសិរីសារនៃពួកកងទ័ពអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យនៅទូទាំងពិភពលោក ។ បន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ ទ្រង់បានលេចចេញមកកាន់ពួកសិស្សទាំងដប់មួយនាក់របស់ទ្រង់ ។ ទ្រង់អាចប្រទានជាពាក្យដំបូន្មានណាមួយ ជាការបង្ហាញណាមួយ ឬជាការព្រមានណាមួយដល់ពួកគេ តាមដែលទ្រង់ជ្រើសរើសនឹងផ្តល់ឱ្យ ។ ប៉ុន្តែតើទ្រង់មានបន្ទូល អ្វីខ្លះទៅ? វាមានកត់ត្រានៅក្នុងម៉ាថាយ 28:18--20 ។ ទ្រង់បានមានបន្ទូលដូចខាងក្រោម:...

"'ចូរទៅបញ្ចុះបញ្ចូលឱ្យ មានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឱ្យ ដោយនូវព្រះនាមនៃព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ :

"'បង្រៀនពួកគេឱ្យគេកាន់តាមគ្រប់ទាំងសេចក្តី ដែលខ្ញុំបានបង្គាប់មកអ្នករាល់គ្នាផង ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់ចុងបំផុតកល្ប'" ។

ប្រធានម៉នសុនបានបន្តថា:

"នេះជាការសន្យា! បើយើងឆ្លើយតបដោយអះអាងចំពោះការហៅពិសិដ្ឋនោះ ចំពោះសិទ្ធិអំណាចចងភ្ជាប់នោះ នោះ 'ខ្ញុំនឹងគង់នៅជាមួយអ្នកជានិច្ច រហូតដល់ចុងបំផុតនៃផែនដី' ។ ខ្ញុំគិតថាគ្មានការសន្យាណាអស្ចារ្យជាងនេះទៀតទេ" ("The Five M's of Missionary Work" *New Era* ខែ មិនា ឆ្នាំ 2007 ទំព័រ 42) ។

នៅក្នុងព្រះគម្ពីរមរមន ដោយដកស្រង់ពាក្យសម្ដីរបស់ស៊ីណូស នោះយ៉ាកុបបាននិយាយអំពីកិច្ចការរបស់យើងនៅសព្វថ្ងៃនេះ ជារូបបាធិដ្ឋានអំពីមែកដើមអូលីវស្រុក និងមែកដើមអូលីវព្រៃថា :

"ហេតុដូច្នេះហើយ ចូរទៅចុះ ហើយហៅពួកអ្នកបំរើឯទៀតមក ដើម្បីយើងអាចព្យាយាមធ្វើការដោយសមត្ថភាពរបស់យើង នៅក្នុងចំការ ប្រយោជន៍យើងអាចរៀបចំផ្លូវ ដើម្បីយើងអាចផ្ដល់ផ្លែឈើធម្មជាតិម្ដងទៀត គឺជាផ្លែធម្មជាតិល្អ ហើយវិសេសបំផុតជាងផ្លែណាៗទាំងអស់ ។

"ហេតុដូច្នោះហើយ ចូរយើងទៅចុះ ហើយធ្វើ ការដោយសមត្ថភាពរបស់យើង ជាលើកចុងក្រោយបង្អស់ ត្បិតមើលចុះ ទីបញ្ចប់ខិតជិតមកដល់ហើយ ហើយនេះជា លើកចុងក្រោយបង្អស់ ដែលយើងនឹងកាត់លួសក្នុងចំការយើង (យ៉ាកុប 5:61--62) ។

ការហៅរបស់ព្រះអង្គសង្គ្រោះ គឺចំពោះអ្នកដែលជាជំនាន់កំពុងពេញវ័យ ។ ទ្រង់កំពុងតែសុំដល់យុវជន និងយុវនារីឱ្យមានភាពសក្ដិសម រៀបចំខ្លួន និងស្មោះត្រង់ ដែលនឹងស្ដាប់តាមសម្លេងរបស់ព្យាការី ដែលនឹងបំពេញតាមសំណូមពរ ហើយនិយាយដូចដែលព្រះអង្គសង្គ្រោះផ្ទាល់បានមានបន្ទូលថា "ទូលបង្គំនៅឯណេះហើយ សូមចាត់ទូលបង្គំចុះ" (អ័ប្រាហាំ 3:27) ។ មិនដែលមានតំរូវការធំជាងនេះទេ ។ ស្រែមិនដែលទុំជាងនេះទៀតទេ ។ អ្នកត្រូវបានហៅឱ្យទៅ "នៅគ្រាចុងក្រោយនេះ" (យ៉ាកុប 5:62) ។ គ្មានការហៅ ឬកិច្ចការណាមួយធំជាងការបង្រៀនពី "ការទៅបញ្ចុះបញ្ចូល ឱ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឱ្យ ដោយនូវព្រះនាមនៃព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ" នោះទេ (ម៉ាថាយ 28:19) ។

ខ្ញុំប្រកាសដោយឧឡារិក ហើយធ្វើទីបន្ទាល់ថា ស្ថានសួគ៌បើកចំហរ ថាព្រះមិនមែនគ្រាន់តែបានមានព្រះបន្ទូលប៉ុណ្ណោះនោះទេ ប៉ុន្តែថាទ្រង់មានបន្ទូលនៅសព្វថ្ងៃនេះ ។ ព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ ហើយកំពុងតែអញ្ជើញអ្នកដូចជាទ្រង់បានអញ្ជើញដល់ពួកសាវកពីជំនាន់មុនរបស់ទ្រង់ ពេត្រុស និងអនទ្រេថា: "ចូរមកតាមខ្ញុំ ខ្ញុំនឹងតាំងអ្នកឱ្យជាអ្នកនេសាទមនុស្សវិញ" (ម៉ាថាយ 4:19) ។ សូមឱ្យអ្នកឆ្លើយតប ដូចដែលពួកគេបានឆ្លើយតប ដោយការទុកសំណាញ់របស់អ្នកចោលទៅតាមទ្រង់ភ្លាម ។

ខ្ញុំអធិស្ឋានសុំឱ្យអ្នកដែលជាជំនាន់កំពុងពេញវ័យ នឹងក្រោកឈរឡើងសំរាប់សេចក្ដីពិត និងសេចក្ដីសុចរិត ហើយយល់អំពីការហៅដ៏ពិសិដ្ឋរបស់អ្នក ដើម្បីទៅ ហើយបង្រៀនដល់គ្រប់ទាំងសាសន៍ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។